**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

6

# កិច្ចព្រមព្រៀង

**រវាង**

**រោងចក្រ អេវ៉ាយស៊ី ហ្គាម៉ិន ហ្វេកធើរី ឯ.ក**

**និង**

**តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំរោងចក្រ អេវ៉ាយស៊ី ហ្គាម៉ិន ហ្វេកធើរី ឯ.ក**

**ស្តីពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃ ពុធ ១០កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង០៩ និង០០នាទីព្រឹក នៅក្នុងរោងចក្រ **អេវ៉ាយស៊ី ហ្គាម៉ិន ហ្វេកធើរី ឯ.ក** មានកិច្ចប្រជុំមួយរវាង តំណាងក្រុមហ៊ុននិង តំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ លោកនាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថាៈ ដោយសារតែក្រុមហ៊ុនយើងមិនមានការបញ្ជាទិញគ្រប់គ្រាន់សម្រាប់ផលិត ដែលមិនអាចឱ្យចង្វាក់ផលិតកម្មរបស់រោងចក្រទាំងមូលដំណើរការបាន។ ទើបក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតសរុប ចំនួន៥៨៨នាក់ ស្រីចំនួន៤២៤នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន៥៨៨នាក់ ស្រីចំនួន៤២៤នាក់ រយៈពេលចំនួន៤៩ថ្ងៃ គឺចាប់ពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ ។ នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួល យកការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល **ចំនួន៤០ដុល្លារ (សែសិបដុល្លារអាមេរិកគត់)** ក្នុង១ខែ សម្រាប់ កម្មករនិយោជិតម្នាក់ៗ ហើយបើកឱ្យកម្មករនិយោជិតនៅថ្ងៃទី១០ នៃខែបន្ទាប់ ។

អង្គប្រជុំបានបញ្ចប់នូវវេលាម៉ោង១០ និង០០នាទី នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងមានការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និងសហការណ៍គ្នាយ៉ាងរលូន ៕

នៅថ្ងៃ ពុធ ១០កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
កណ្តាល ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣

**តំណាងកម្មករ និងតំណាងសហជីព**
**ស្នាមមេដៃ**

**នាយកក្រុមហ៊ុន**

ក្រុមហ៊ុន អេវ៉ាយស៊ី ហ្គាម៉ិន ហ្វេកធើរី ឯ.ក
AYC GARMENT FACTORY CO., LTD.
KINGDOM OF CAMBODIA